# សុន្ទរកថា
# របស់ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងកិច្ចប្រជុំនៃរដ្ឋសភា នីតិកាលទី ៧
# ដើម្បីបោះឆ្នោតជ្រើសតាំង ប្រធាន និង អនុប្រធាន នៃរដ្ឋសភា, ប្រធាន និង អនុប្រធាន គណៈកម្មការជំនាញនៃរដ្ឋសភា;
# និង
# ផ្តល់សេចក្តីទុកចិត្ត ចំពោះរាជរដ្ឋាភិបាលកម្ពុជា
# រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣

- លោកជំទាវ កិត្តិសង្គហបណ្ឌិត **ឃួន សុដារី** ប្រធានរដ្ឋសភា;
- ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី ១ រដ្ឋសភា;
- ឯកឧត្តម **វង សូត** អនុប្រធានទី ២ រដ្ឋសភា;
- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**;
- សម្តេចចៅហ្វាវាំង **គង់ សំអុល**;
- សម្តេចក្រឡាហោម **ស ខេង**;
- សម្តេចពិជ័យសេនា **ទៀ បាញ់**;
- សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**;
- សម្តេច, ព្រះអង្គម្ចាស់, ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃរដ្ឋសភា ជាទីមេត្រី !

ថ្ងៃនេះ គឺជាទិវាប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់ព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា នីតិកាលទី ៧ បានបើកសម័យប្រជុំពេញអង្គរបស់ខ្លួន ដើម្បីអនុម័តជ្រើសតាំងសមាសភាពនៃថ្នាក់ដឹកនាំរដ្ឋសភា និង ផ្តល់សេចក្តីទុកចិត្តចំពោះសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា ។

ក្នុងឋានៈជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលទើបទទួលបាននូវសេចក្តីទុកចិត្ត ពីសំណាក់រដ្ឋសភានៅពេលនេះ, ទូលព្រះបង្គំជាខ្ញុំ សូមសម្តែងនូវកតញ្ញូតាធម៌ និង

កតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈ ដែលជានិច្ចកាល ព្រះអង្គទ្រង់បានប្រោសព្រះរាជទាន នូវការគាំទ្រ និង ការលើកទឹកចិត្តដ៏កក់ក្តៅបំផុត ចំពោះរាល់សកម្មភាពរបស់រាជរដ្ឋាភិបាល តាមគន្លងប្រកបដោយគតិបណ្ឌិត និង សុភនិច្ឆ័យ របស់ **ព្រះបរមរតនកោដ្ឋ ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ, ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ទូលព្រះបង្គំជាខ្ញុំ សូមប្រសិទ្ធពរជ័យបវរមហាប្រសើរថ្វាយ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈ និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ សូមព្រះអង្គទ្រង់បានប្រកបដោយព្រះសុខភាពល្អបរិបូរ និង ព្រះកាយពលមាំមួន ដើម្បីបន្តគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំ សម្រាប់កូនចៅ ចៅទួត របស់ព្រះអង្គ ជ្រកកោន ជាយូរអង្វែងតរៀងទៅ ។

ខ្ញុំក៏ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ដែលបានបំពេញតួនាទីជាព្រឹទ្ធសមាជិករដ្ឋសភា ប្រកបដោយប្រសិទ្ធភាព និង ដោយជោគជ័យ ព្រមទាំងសូមថ្លែងអំណរគុណជូនចំពោះ សម្តេច, ព្រះអង្គម្ចាស់, ឯកឧត្តម, លោកជំទាវ ទាំងអស់ ជាថ្នាក់ដឹកនាំ និង ជាសមាជិក-សមាជិកានៃស្ថាប័ននីតិប្បញ្ញត្តិដ៏ឧត្តុង្គឧត្តមនេះ ដែលបានបោះឆ្នោតផ្តល់ការទុកចិត្ត ដល់ **រាជរដ្ឋាភិបាលកម្ពុជា នីតិកាល ទី ៧ នៃរដ្ឋសភា** ដោយមានរូបខ្ញុំជាប្រមុខ ។

ជាមួយគ្នានេះដែរ, ក្នុងនាមខ្លួនខ្ញុំផ្ទាល់ និង ក្នុងនាមសហការីទាំងអស់ នៅក្នុងសមាសភាពនៃរាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ខ្ញុំសូមយកឱកាសដ៏កម្រនេះ សម្តែងនូវអំណរគុណ និង ការគោរពដឹងគុណ ដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា** ព្រមទាំង **សម្តេច, ឯកឧត្តម, លោកជំទាវ ជាថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា** ដែលបានផ្តល់នូវការជឿទុកចិត្ត និង ភារកិច្ចដ៏ឧត្តុង្គឧត្តម ដល់យើងខ្ញុំទាំងអស់គ្នា ឱ្យបន្តវេននៅក្នុងការបំពេញបេសកកម្មជាតិដ៏ថ្លៃថ្លា

បំផុតនេះ ឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា ក៏ដូចជាឆន្ទៈគាំទ្រយ៉ាងពេញទំហឹង ពីសំណាក់ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់ជាន់ថ្នាក់ ចំពោះគោលនយោបាយ និង ការដឹកនាំប្រទេសជាតិ របស់គណបក្សប្រជាជនកម្ពុជា ។ ជាការពិត, ការតស៊ូលះបង់ដ៏ធំធេងមិនអាចកាត់ថ្លៃបាន និង ការប្រឹងប្រែងយកអស់កម្លាំងកាយ, ចិត្ត, ប្រាជ្ញា និង ស្មារតី ដើម្បីបុព្វហេតុនៃការរំដោះជាតិ និង ប្រជាជនពីក្រញាំបិសាចនៃរបបប្រល័យពូជសាសន៍ដ៏សាហាវយង់ឃ្នង; ការការពារឯករាជ្យ, អធិបតេយ្យ និង បូរណភាព ទឹកដី; ការនាំមកនូវសុខសន្តិភាព, ការឯកភាពជាតិ, ការបង្រួបបង្រួមជាតិពេញលេញ; ការការពារអាយុជីវិត និង ការធានាលំនឹងជីវភាព របស់ប្រជាជន; ព្រមទាំងការជំរុញនូវកិច្ចអភិវឌ្ឍឈានទៀងឥតឈប់ឈរ ជូនមាតុប្រទេសនៃយើង; គឺជាគំរូវីរភាពដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តម សម្រាប់យើងខ្ញុំទាំងអស់គ្នាជាអ្នកបន្តវេនជំនាន់ក្រោយ យកតម្រាប់តាម ។ ច្បាស់ណាស់ថា គតិបណ្ឌិតដ៏ភ្លឺស្វាង, បទពិសោធន៍ដ៏សម្បូរបែប, ភាពប្រាកដនិយម, ភាពប៉ិនប្រសប់, ភាពឈ្លាសវៃគ្មានគូប្រៀប និង ភាពមុតស្រួច នៅក្នុងរាល់ចំណាត់ការនានា របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក៏ដូចជារបស់ **សម្តេច, ឯកឧត្តម និង លោកជំទាវ ថ្នាក់ដឹកនាំឯទៀត** នៅក្នុងការដឹកនាំប្រទេសជាតិ គឺជា **កំពូលឯតទគ្គកម្មខាងសិល្បៈនៃការដឹកនាំ** ដែលយើងខ្ញុំទាំងអស់គ្នាជាអ្នកបន្តវេន ពិតមិនអាចនឹងប្រៀបផ្ទឹមបាននោះឡើយ ។ ក៏ប៉ុន្តែ គំរូវីរភាព និង សមត្ថភាពដឹកនាំដ៏ខ្ពង់ខ្ពស់ ព្រមទាំងការជឿទុកចិត្តមកលើយើងខ្ញុំទាំងអស់គ្នានេះ នឹងដើរតួជាកត្តាអចិន្ត្រៃយ៍នៅក្នុងសម្បជញ្ញៈ និង មនសិការ របស់យើងខ្ញុំ ដែលនឹងជួយដាស់តឿន, ដុសសំលៀង និង ពង្រឹងជាប់ជាប្រចាំ នូវឆន្ទៈមោះមុតឥតរាថយ និង ការប្តេជ្ញាចិត្តឥតងាករេ ព្រមទាំងនឹងជួយជំរុញយើងខ្ញុំឱ្យប្រឹងប្រែងអស់ពីលទ្ធភាព, ជាមួយនឹងថាមពលយុវវ័យ និង សមត្ថភាពខាងចំណេះវិជ្ជា និង ជំនាញ ដែលខ្លួនមាន, ដើម្បីបំពេញបេសកកម្មជាតិដ៏ឧត្តុង្គ-ឧត្តមនេះ ឱ្យសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ ស័ក្តិសមទៅនឹងបំណងប្រាថ្នា និង អាណត្តិកិច្ច ដែលប្រជាពលរដ្ឋខ្មែរដ៏ច្រើនកុះករ នៅទូទាំងប្រទេស ប្រគល់ជូន ។

***សម្តេច, ព្រះអង្គម្ចាស់, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

ការបោះឆ្នោតនាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០២៣ កន្លងទៅថ្មីៗនេះ គឺជាការបោះឆ្នោតមួយ ដែលមានលក្ខណៈសេរី, យុត្តិធម៌, ត្រឹមត្រូវ និង មានតម្លាភាព ដោយមានប្រជាពលរដ្ឋចូលរួម រហូតដល់ជាង ៨ លាន ២ សែន នាក់, ត្រូវជាប្រមាណ ៨៤,៥៩% នៃចំនួនប្រជា-ពលរដ្ឋមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោត របស់ **គជប** ហើយក្នុងនេះ សម្លេងឆ្នោតគាំទ្រ

គណបក្សប្រជាជនកម្ពុជា មានរហូតដល់ទៅប្រមាណ ៨២,៣ %។ ជាការពិត, នេះ គឺជាអត្រាមួយដ៏ខ្ពស់ ធៀបទៅនឹងប្រវត្តិថ្មីៗនៃការចូលរួមបោះឆ្នោត នៅកម្ពុជាខ្លួនឯង ក៏ដូចជានៅក្នុងប្រទេសជាច្រើនផ្សេងទៀតលើសកលលោក ។ អត្រានៃការចូលរួមដ៏ខ្ពស់នេះ បានបង្ហាញឱ្យឃើញច្បាស់ នូវឆន្ទៈដ៏ស្រួចស្រាល់របស់ប្រជាជនកម្ពុជាយ៉ាងច្រើនកុះករ ក្នុងការអនុវត្តសិទ្ធិជាពលរដ្ឋរបស់ខ្លួន ស្របតាមការកំណត់នៃរដ្ឋធម្មនុញ្ញ ដើម្បីជ្រើសរើសគណបក្សនយោបាយ និង ឥស្សរៈជននយោបាយ ដឹកនាំប្រទេស តាមគន្លងនៃលទ្ធិប្រជាធិបតេយ្យ និង នីតិរដ្ឋ ។ ប្រការនេះ ក៏ជាសក្ខីកម្មដ៏ប្រចក្ស, គូសរំលេចយ៉ាងត្រដែត, នូវទឹកចិត្តរបស់ប្រជាជាតិកម្ពុជាទាំងមូល ដែលស្រឡាញ់សុខសន្តិភាព និង គោរពគាំទ្រយ៉ាងខ្ជាប់ខ្ជួន នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និង នីតិរដ្ឋ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ហើយក៏ជាការឆ្លុះបញ្ចាំងឱ្យឃើញ ពីការបដិសេធយ៉ាងដាច់អហង្ការ, ពីសំណាក់ប្រជាពលរដ្ឋដ៏ច្រើនលើសលុប, ចំពោះទង្វើអគតិរបស់ក្រុមជនមួយចំនួន ដែលបានខិតខំទាក់ទាញប្រជាជាតិកម្ពុជា ឱ្យចាកចេញពីគន្លងនៃមាគ៌ាប្រជាធិបតេយ្យ និង នីតិរដ្ឋ ហើយញុះញង់, អុជអាល, បំផុស ប្រជាពលរដ្ឋ ឱ្យលុះទៅនឹងមហិច្ឆតាផ្ទាល់ខ្លួនរបស់ពួកគេ ដែលប្រកបទៅដោយពិសពុល និង គ្រោះថ្នាក់បំផុត សម្រាប់ប្រទេសជាតិ ។

បន្ថែមលើនេះ, លទ្ធផលនៃការបោះឆ្នោតកាលពីថ្ងៃទី ២៣ ខែ កក្កដា កន្លងទៅនេះ ក៏ជាការឆ្លុះបញ្ចាំងឱ្យឃើញផងដែរ នូវឆន្ទៈគាំទ្រយ៉ាងពេញទំហឹង និង ដ៏មោះមុត ពីសំណាក់ប្រជាពលរដ្ឋ ភាគច្រើនលើសលុប និង ពីគ្រប់មជ្ឈដ្ឋាន ទៅលើភាពចាំបាច់ក្នុងការបន្តកិច្ចដឹកនាំកសាងប្រទេស នៅលើមាគ៌ានៃសុខសន្តិភាព, ការអភិវឌ្ឍ និង ការកែទម្រង់ក្នុងគ្រប់វិស័យ ឆ្ពោះទៅរកវឌ្ឍនភាព និង វិបុលភាព កាន់តែរុងរឿង ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា មានកាតព្វកិច្ចបន្តបេសកកម្មដ៏ឧត្តុង្គឧត្តម ជាប្រវត្តិសាស្ត្រ, ក្នុងការប្តេជ្ញាចិត្តឥតរាថយ និង ក្នុងភាពកាន់តែស្វាហាប់, ដើម្បីពន្លឿនកិច្ចអភិវឌ្ឍ និង ជំរុញអនុវត្តការកែទម្រង់ ឱ្យកាន់តែស៊ីជម្រៅ និង កាន់តែទូលំទូលាយ ។ គឺនៅក្នុងស្មារតីនេះហើយ ដែលរាជរដ្ឋាភិបាលបានរៀបចំឡើង នូវ «**កម្មវិធីនយោបាយ**» របស់ខ្លួន ដោយផ្អែកលើ «**កម្មវិធីនយោបាយសម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨**» ដែលគណបក្សប្រជាជនកម្ពុជា បានប្រកាសដាក់សុំការគាំទ្រពីជនរួមជាតិ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត នាខែ កក្កដា កន្លងទៅ ។ នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ,ខ្ញុំសូមដាក់ជូនអង្គរដ្ឋសភាជាទីគោរព នូវ «**កម្មវិធីនយោបាយរបស់រាជ-**

**រដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា**» ជាលាយលក្ខណ៍អក្សរ និង សូមការអនុញ្ញាត កត់ត្រាឯកសារដ៏មានសារៈសំខាន់នេះ ក្នុងកំណត់ហេតុផ្លូវការនៃសម័យប្រជុំពេញអង្គរបស់រដ្ឋសភា ដោយអនុគ្រោះ ។

ខ្លឹមសារនៃ «**កម្មវិធីនយោបាយ**» របស់រាជរដ្ឋាភិបាល ដែលត្រូវបានបង្ហាញជូនរដ្ឋសភា, និង តាមរយៈរដ្ឋសភា, ជូនដល់ជនរួមជាតិ និង សាធារណៈមតិទូទៅ នាពេលនេះ, ឆ្លុះបញ្ចាំងអំពីគោលបំណង ឧត្តមគតិ និង ការប្តេជ្ញាចិត្ត ដ៏មោះមុត របស់រាជរដ្ឋាភិបាល ក្នុងការពុះពារបម្រើជាតិ និង ប្រជាជន ក្នុងគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញច្បាស់អំពីចក្ខុវិស័យ និង គោលនយោបាយលើគ្រប់វិស័យ របស់រាជរដ្ឋាភិបាល ដើម្បីបន្តការពារ និង កសាងមាតុភូមិឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង ស្របតាមឆន្ទៈ និង បំណងប្រាថ្នារបស់ប្រជាជន ។ ជារួម, ខ្ញុំសូមអនុញ្ញាតយកឱកាសនេះ គូសបញ្ជាក់អំពីការធានា ៥ យ៉ាង របស់រាជរដ្ឋាភិបាល ជូនដល់បងប្អូនជនរួមជាតិយើងទាំងអស់ តាមរយៈការដឹកនាំអនុវត្ត «**កម្មវិធីនយោបាយ**» នេះ សម្រាប់ដំណើរទៅមុខរបស់កម្ពុជា នៅក្នុង **នីតិកាលទី ៧ នៃរដ្ឋសភា** នោះគឺ ៖

**ទី១-ការធានាការពារឱ្យបានជាដាច់ខាត នូវសន្តិភាព, ស្ថិរភាព, សន្តិសុខ, និង សុវត្ថិភាព** សម្រាប់ការរស់នៅដោយក្សេមក្សាន្តរបស់ប្រជាជន នៅគ្រប់ទិសទីក្នុងផ្ទៃប្រទេស; **ព្រមទាំងការការពារឯករាជ្យ, អធិបតេយ្យ, និង បូរណភាព ទឹកដី ឱ្យបានគង់វង្សចីរកាល** មិនឱ្យកម្លាំងណាមកបំពាន ឬ បំផ្លាញ បានឡើយ ។

**ទី២-ការធានាបន្តជំរុញអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកម្ពុជា ក្នុងគ្រប់វិស័យ** ដោយផ្តោតអាទិភាពលើ: ការកែទម្រង់អភិបាលកិច្ច សំដៅពង្រឹងស្ថាប័នសាធារណៈ ដែលមានសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ រួមបញ្ចូលផងដែរ នូវការពង្រឹងគោលការណ៍នីតិរដ្ឋ និង ការពង្រឹងយុត្តិធម៌ក្នុងសង្គម ព្រមទាំងការបង្កើនប្រសិទ្ធភាព និង ការលើកកម្ពស់គុណភាពសេវាសាធារណៈ; ការពង្រឹងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដែលមានស្ថិរភាពរឹងមាំ ធន់នឹងវិបត្តិ និង ទ្រទ្រង់ដល់កំណើនខ្ពស់ ប្រកបដោយចីរភាព បរិយាប័ន្ន និង សមធម៌; ការបន្តផ្តល់អាទិភាពខ្ពស់ ទៅលើការវិនិយោគលើមូលធនមនុស្ស ដោយផ្តោតលើការកែទម្រង់វិស័យអប់រំ និង វិស័យសុខាភិបាល; ការលើកកម្ពស់ និង ការបង្កើនការវិនិយោគ, ទាំងការវិនិយោគសាធារណៈ ទាំងការវិនិយោគឯកជន, លើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា, ទាំងផ្នែករឹង ទាំងផ្នែកទន់, ដើម្បីបង្កើនភាពទាក់ទាញ និង គាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ក៏ដូចជាបម្រើដល់សេចក្តីត្រូវការគ្រប់ផ្នែករបស់ប្រជាជន; ការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង ការបង្កើត

បរិយាកាសអំណោយផលដល់សហគ្រាសធុនមីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី ឱ្យរីកលូតលាស់; ការលើកកម្ពស់ភាពជាដៃគូ រវាងរដ្ឋ និង វិស័យឯកជន; ការបង្កើនភាពស៊ីជម្រៅ និង ការពង្រឹងភាពធន់ហិរញ្ញវត្ថុ ព្រមទាំងការពង្រីកបរិយាប័ន្នហិរញ្ញវត្ថុ រួមបញ្ចូលនូវការរៀបចំ និង ការកែលម្អក្របខ័ណ្ឌ និង យន្តការហិរញ្ញប្បទាន ព្រមទាំងការធ្វើពិពិធកម្មផលិតផល និង សេវាហិរញ្ញវត្ថុ សំដៅរួមចំណែកជំរុញសកម្មភាពសេដ្ឋកិច្ច និង ការវិនិយោគ; និង ការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។ល។

**ទី៣-ការធានាបន្តជំរុញលើកកម្ពស់ និង កែលម្អជីវភាពរបស់ប្រជាជន** តាមរយៈការផ្តល់ជូនដល់ស្រទាប់យុវជន នូវការអប់រំ និង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ប្រកបដោយគុណភាព ព្រមជាមួយនឹងឱកាសទទួលបានការងារធ្វើ; ការជួយកសិករក្នុងការពង្រីកផលិតកម្ម និង ការរកទីផ្សារលក់កសិផល ដោយថ្លៃសមរម្យ, ការបន្តដំឡើងប្រាក់ឈ្នួលអប្បបរមា និង ប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ព្រមជាមួយនឹងការកែលម្អលក្ខខណ្ឌការងារ និង ការការពារអាជីព ជូនកម្មករ-និយោជិត; ការបន្តដំឡើងបៀវត្សអប្បបរមា និង ប្រាក់សោធននិវត្តន៍ជូនមន្ត្រីរាជការសាធារណៈគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និង អតីតយុទ្ធជន គួបផ្សំជាមួយនឹងការរៀបចំប្រព័ន្ធបៀវត្ស និង ប្រព័ន្ធលើកទឹកចិត្ត ក្នុងវិស័យសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព និង ភាពគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើគុណាធិបតេយ្យ សំដៅលើកកម្ពស់ផលិតភាពការងារ, សមិទ្ធកម្ម និង ជីវភាពមន្ត្រីសាធារណៈ ឱ្យមានសង្គតិភាព ជាមួយកំណើនសេដ្ឋកិច្ច និង លទ្ធភាពនៃថវិកាជាតិ ។ល។

**ទី៤-ការធានានូវសុវត្ថិភាពសង្គម និង លំនឹងក្នុងការរស់នៅរបស់ប្រជាជន, ទាំងនាបច្ចុប្បន្ន ក៏ដូចជាទៅអនាគត,** តាមរយៈការអភិវឌ្ឍ និង ការពង្រឹងប្រព័ន្ធគាំពារសង្គម, ដែលរួមបញ្ចូលនូវ របបជំនួយសង្គម និង របបសន្តិសុខសង្គម, ប្រកបដោយប្រសិទ្ធភាព និង ចីរភាព ដែលជួយគាំពារប្រជាជនគ្រប់រូប, ជាពិសេស គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះ និង គ្រួសារងាយរងហានិភ័យ, ពីគ្រោះអាសន្ន និង វិបត្តិនានា ដោយមិនទុកឱ្យប្រជាជនណាម្នាក់ទទួលរងគ្រោះដោយមិនមានការយកចិត្តទុកដាក់នោះឡើយ ។

**ទី៥-ការធានាបង្កើនការយកចិត្តទុកដាក់ដល់ ចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ការកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ** តាមរយៈ ការប្រើប្រាស់ឱ្យបានប្រសើរបំផុតនូវ ផលលាភប្រជាសាស្ត្រ និង ការពង្រឹងភាពធន់នៃប្រជាសាស្ត្រ របស់កម្ពុជា; ការលើកកម្ពស់សមភាពយេនឌ័រ; ការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយចីរភាព; ការខិតខំបង្កើនហិរញ្ញប្ប-

ទានចីរភាព សំដៅជំរុញការវិនិយោគបៃតង និង សេដ្ឋកិច្ចបៃតង; ការជំរុញការវិនិយោគសាធារណៈ ដែលមានភាពធន់នឹងអាកាសធាតុ និង មានការបញ្ចេញកាបូនទាប; និង ការធានាចីរភាពបរិស្ថាន ព្រមទាំងការត្រៀមខ្លួនជាស្រេច ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃការប្រែប្រួលអាកាសធាតុ ។ ជាមួយគ្នានេះ, ក្នុងនាមជាប្រមុខនៃរាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា, ខ្ញុំក៏សូមសន្យា និង ធ្វើការប្តេជ្ញា ជាឱឡារិក ជូនបងប្អូនជនរួមជាតិទូទាំងប្រទេសថា ខ្ញុំនឹងប្តូរផ្តាច់ដឹកនាំស្ថាប័ននីតិប្រតិបត្តិរបស់ជាតិ, ធានាអនុវត្តឱ្យបានសម្រេចជោគជ័យ នូវ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល**» ដែលជាការសន្យារបស់គណបក្សប្រជាជនកម្ពុជា ជូនដល់ប្រជាពលរដ្ឋ នៅមុនការបោះឆ្នោត, ហើយដែលខ្ញុំបានដាក់ជូនអង្គរដ្ឋសភាដ៏ឧត្តុង្គឧត្តម នាពេលនេះ, ពិសេស ដោយផ្តោតការយកចិត្តទុកដាក់លើ **កម្មវិធីគោលនយោបាយជាអាទិភាព ទាំង ៦** ដែលនឹងត្រូវបានដាក់ឱ្យចាប់ផ្តើមអនុវត្តភ្លាម នៅក្នុងឆ្នាំ ២០២៣ នេះ រួមមាន ៖

(១). ការពង្រីកសេវាថៃទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល;

(២). ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស;

(៣). ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន;

(៤). ការដាក់ចេញ និង ការជំរុញ អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ;

(៥). ការដាក់ចេញនូវយន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ; និង

(៦). ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស និង ការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ ។

*សម្តេច, ព្រះអង្គម្ចាស់, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !*

ក្នុងនាមរាជរដ្ឋាភិបាល, ខ្ញុំសូមអំពាវនាវដល់អង្គរដ្ឋសភាទាំងមូល, និង តាមរយៈរដ្ឋសភា, សូមអំពាវនាវដល់ជនរួមជាតិកម្ពុជាគ្រប់ស្រទាប់, ទាំងនៅក្នុង និង ក្រៅប្រទេស; ហើយក៏ឆ្លៀតក្នុងឱកាសនេះដែរ សូមអំពាវនាវដល់មន្ត្រីគ្រប់ជាន់ថ្នាក់ នៅតាមបណ្តាក្រសួង និង ស្ថាប័ននានា នៃអង្គនីតិប្បញ្ញត្តិ, អង្គនីតិប្រតិបត្តិ, អង្គតុលាការ, កងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទ, និង ស្ថាប័នថ្នាក់ក្រោមជាតិ គ្រប់លំដាប់ថ្នាក់, ព្រមទាំង ដៃគូ និង តួអង្គអភិវឌ្ឍន៍ទាំងអស់ ដែលក្នុងនោះរួមមាន ដៃគូទ្វេភាគី និង ពហុភាគី, វិស័យឯកជន, អង្គការមិនមែនរដ្ឋាភិបាល, មេត្តាផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹង និង ចូលរួមអនុវត្តយ៉ាងសកម្ម នូវ «**កម្មវិធីនយោបាយ**» នេះ ឱ្យទៅជាចលនារួមដ៏ខ្លាំងក្លា, ប្រកបដោយជវភាព, សំដៅសម្រេចឱ្យបាននូវជោគជ័យជាផ្លែផ្កា សម្រាប់ជាឧត្តមប្រយោជន៍ជូនប្រជាជនកម្ពុជា ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលនឹងដាក់ចេញ ព្រមទាំងនឹងជំរុញអនុវត្តឱ្យបានជោគជ័យ នូវ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» ដែលជា **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** នៃ «**កម្មវិធីនយោបាយ**» នេះ សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា ។

ជាថ្មីម្តងទៀត, រាជរដ្ឋាភិបាលកម្ពុជាសូមសម្តែងនូវសេចក្តីគោរព និង ការដឹងគុណ ដ៏ជ្រាលជ្រៅបំផុត ជូនជនរួមជាតិនៅគ្រប់ទិសទី ដែលបានឃើញយ៉ាងច្បាស់នូវសច្ចភាពនៃការរស់ឡើងវិញ និង ការរីកចម្រើនរបស់ប្រទេសជាតិ ហើយបានផ្តល់ជំនឿ និង ការគាំទ្រដ៏ធំធេង ចំពោះរាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា នៅគ្រប់ដំណាក់កាល ។ ដោយផ្អែកលើមូលដ្ឋាននៃការគាំទ្ររបស់ប្រជាជន, រាជរដ្ឋាភិបាលប្តេជ្ញាប្រមូលផ្តុំកម្លាំង ប្រឹងប្រែងជំរុញអនុវត្តបេសកកម្មជាប្រវត្តិសាស្ត្រ នៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភានេះ ឱ្យបានសម្រេចជោគជ័យដ៏ត្រចះត្រចង់ ។

ជាទីបញ្ចប់, ខ្ញុំសូមគោរពជូនពរ សម្តេច, ព្រះអង្គម្ចាស់, ឯកឧត្តម, លោកជំទាវ, ប្រធាន, អនុប្រធាន រដ្ឋសភា ព្រមទាំងសមាជិក-សមាជិកានៃរដ្ឋសភាទាំងមូល, បានសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ : អាយុ, វណ្ណៈ, សុខៈ, ពលៈ និង សូមសម្រេចបានជោគជ័យ ក្នុងគ្រប់ភារកិច្ចបម្រើជាតិ និង មាតុភូមិ ។

**សូមអរគុណ**!

# Remarks
# By
# H.E. Kitti Tesaphibal Bindit HUN MANET
# Prime Minister of the Kingdom of Cambodia
# At the Meeting of the Seventh Legislature of the National Assembly
# To Elect the President and Vice President of the National Assembly,
# Chairmen and Vice Chairmen of the National Assembly's Commissions,
# And
# Upon Receiving the Vote of Confidence for
# the Royal Government of Cambodia

Phnom Penh, 22nd August 2023

- *Your Excellency Kitti Sangaha Bindit **KHUON Sudary**, President of the National Assembly;*
- *Your Excellency Kitti Setha Bindit **CHEAM Yeap**, First Vice President of the National Assembly;*
- *Your Excellency **VONG Soth**, Second Vice President of the National Assembly;*
- *Samdech Akka Moha Sena Padei Techo **HUN Sen**;*
- *Samdech Chaufea Veang **KONG Sam Ol**;*
- *Samdech Krolahom **SAR Kheng**;*
- *Samdech Pichey Sena **TEA Banh**;*
- *Samdech Kittisangaha Bindit **MEN Sam An**;*
- *Samdech, Prince, Excellencies, Members of the National Assembly !*

Today marks a historical moment for the Kingdom of Cambodia, as the Seventh Legislature of the National Assembly holds its plenary session to elect leaders of the National Assembly, and to cast the vote of confidence for members of the Royal Government of Cambodia of the Seventh Legislature of the National Assembly.

As the **Prime Minister of the Kingdom of Cambodia** who has just received the vote of confidence from the National Assembly, I would like to extend my warmest gratitude and appreciation to the revered **His Majesty Preah Bat Samdech Preah Boromneath NORODOM SIHAMONI, King of the Kingdom of Cambodia,** for always supporting and encouraging the Royal Government of Cambodia.

This is indeed the wisdom and judicious examples set forth by the most revered **"Preah Borom Ratanak Kaudh", His Majesty Preah Bat Samdech Preah NORODOM SIHANOUK, Heroic King, Father of Independence, Territorial Integrity and Unity of the Khmer Nation**, and **Her Majesty Samdech Preah Maha Ksatrei Norodom MONINEATH SIHANOUK, Cambodian Queen-Mother with Freedom, Dignity and Happiness.**

Representing the Royal Government of Cambodia, I would like to wish the revered **His Majesty Preah Bat Samdech Preah Boromneath NORODOM SIHAMONI, King of the Kingdom of Cambodia,** as well as **Her Majesty Samdech Preah Maha Ksatrei Norodom MONINEATH SIHANOUK, Cambodian Queen-Mother with Freedom, Dignity and Happiness** good health, strength, intelligent, and longevity, to stay as forever-serene shade for every Cambodian.

I would also like to express my warmest appreciation to **Samdech Akka Moha Ponhea Chakrei HENG SAMRIN** who has effectively and successfully filled the role of the **most Senior National Assembly's Member.** I would also like to extend my appreciation to Samdech, Prince, and Excellencies, the leaders and members of this splendid legislative body, for having casted your vote of confidence for the Royal Government of Cambodia of the Seventh Legislature of the National Assembly, of which I lead.

In addition, on behalf of myself and my colleagues who are members of the Royal Government of Cambodia of the Seventh Legislature of the National Assembly, I would like to take this rare opportunity to express my sincerest appreciation and gratitude to **Samdech Akka Moha Sena Padei Techo HUN SEN, President of the Cambodian People's Party**, as well as **Samdech, Excellencies leaders of the Cambodian People's Party**, for having confidence in us and for entrusting us with this fateful mission to serve our nation, to respond to the needs and wishes of our Cambodian people, and to return their unwavering supports for the Cambodian People's Party's leadership and policies. Indeed, your invaluable sacrifice and efforts, both in terms of strength, mental fortitude, intellect and spirit to rescue our nation and people from the atrocious genocide; your strives to protect our independence, sovereignty and territorial integrity; your commitment to bring peace, national unity and reconciliation; your pledge to protect our people's lives and livelihood; as well as your relentless efforts to develop our motherland are all heroic examples that we, as the future generation, must follow. Undoubtedly, the bright wisdom, diverse experiences, pragmatism, and the levels of adeptness, intelligence and savviness that **Samdech Akka Moha Sena Padei Techo HUN SEN** and **Samdech, Excellencies Leaders** have displayed through leading our nation is a **Mastery of the Art of Leadership**; the one that we as the future generation can only aspire to. Nevertheless, the heroic examples and the ability to lead we have witnessed, and the confidence we have gained will be the permanent fixtures within our consciences and consciousness.

They will constantly sharpen and strengthen our willingness and commitment to strive to our utmost abilities, and to use our youthful energy, knowledge and skills to fulfill this mission, just as what our Cambodian people have wished and mandated.

*Samdech, Prince, Excellencies, Ladies and Gentlemen!*

The recent election on July 23, 2023 was free, fair, just and transparent with more than 8.2 million people voted, which was about 84.59% of the population on the NEC's voter list, of those who voted, 82.3% supported the CPP. Indeed, this is a high turnout rate compared to other elections in recent history, both for Cambodia itself and for many other countries around the world. This high turnout rate underscores the strong will of most Cambodian people who exercised their Constitution's civil rights to entrust their country to political parties and leaders to lead along the path of democracy and the rule of law. This is also a clear testimony, highlighting our nation's peace-loving spirit that firmly supports the principles of liberal democracy, pluralism, and the rule of law, as stated in the Constitution of the Kingdom of Cambodia. This also reflects the outright rejection of most Cambodian people against the brazen acts that tried luring their country away from the path of democracy and the rule of law, as well as any treacherous attempts to incite, provoke and instigate their contempt which endanger their nation.

In addition, the result of the 23rd July election reflects the strong will and overwhelming supports of our citizens to see their country being led toward progressiveness and prosperity, through the path of peace, development and reform in all sectors. In this regard, the Royal Government of Cambodia of the Seventh Legislature of the National Assembly is obligated to be relentlessly and energetically committed to fulfilling this historic mission of accelerating development and pushing for deeper and broader reforms. In this spirit, the Royal Government of Cambodia has put forth its **"Political Platform"** based on the Cambodian People's Party's **"Political Platform for Nation Building and Defense 2023-2028",** that has been announced for supports during the July election. Hence, on this special occasion, I would like to respectfully submit to the National Assembly the **"Political Platform of the Royal Government of Cambodia of the Seventh Legislature of the National Assembly"** in writing, and request permission to record this important document in the official Minutes of the plenary session of the National Assembly, upon your kind approval.

The content of the **"Political Platform"** of the Royal Government of Cambodia, which is being presented to the National Assembly, and through the National Assembly, to the people and the general public, reflects the Royal Government of Cambodia's aspiration, ideals and its strong determination to serve the nation and its people at all circumstances. It also clearly illustrates the Royal Government of Cambodia's visions and policies to protect and build our motherland toward a glorious future, just as what our people aspired. In general, I would like to take this opportunity to highlight **the Five Guarantees** from the Royal Government of Cambodia to all our compatriots, through the implementation of the **"Political Platform"** as we embark on the next journey of the **Seventh Legislature of the National Assembly**, which are:

1. **Ensuring the absolute protection of peace, stability, security and safety** for the well-being of the people; **as well as the protection of independence, sovereignty and territorial integrity** so that no one can infringe or sabotage it.

**2. Ensuring socio-economic development across all sectors** by focusing on: governance reform through moulding our public institutions into ones that are highly capable, strong, smart and clean, while the rule of law, social justice as well as the efficiency and quality of public services are strengthened; strengthening a stable macroeconomic environment that is resilient to crises while supporting high growth with sustainability, inclusiveness and integrity; continuing to prioritize human capital investment, especially through reforms in education and health sectors; promoting and increasing investment, both from public and private sectors, in necessary hard and soft infrastructures that will help attracting and supporting more economic activities while serving the people's needs; paying attention to the development of informal economy, as well as the formation of a conducive environment for micro, small and medium enterprises, and startups to grow; promoting public-private partnerships; deepening and strengthening financial resilience, as well as expanding financial inclusiveness that aims to promote economic activities and investment through refining financing frameworks and mechanisms, as well as financial products and services' diversification; and promoting digital transformation both in terms of social and economic development, etc.

**3- Ensuring improvement of people's livelihood** by providing youth with high quality education and vocational training, as well as job opportunities; assisting farmers in expanding their production and helping them find markets to sell their agricultural products at reasonable price; continuing to raise minimum wage and other benefits along with better-improved working conditions and career protection; continuing to raise the minimum wage and pensions for all public servants, retirees and veterans, as well as developing a more efficient and comprehensive public sector's payroll and incentive system that are based on meritocracy and aligned with the promotion of productivity, performance and livelihood of public servants, economic growth and the availability of national budget.

**4- Ensuring social security and stability in people's livelihood now and in the future** by developing and strengthening a social protection system that includes effective and sustainable social assistance and social security systems to protect everyone, especially those from poor households, vulnerable groups and at-risk households, from crises and emergencies without leaving anyone unattended.

**5- Ensuring more attentions to sustainable socio-economic development and building resilience to climate change** by making the best use of demographic dividends and the strengthening Cambodia's demographic resilience; promoting gender equality; sustainably managing natural resources; increasing sustainable financing that promotes green investment and economy; promoting climate-resilient and low-carbon public investment; and ensuring environmental sustainability, as well as the readiness to respond to climate change.

At the same time, as the Head of the Royal Government of Cambodia for the Seventh Legislature of the National Assembly, I would also like to solemnly pledge and commit to all compatriots that I will lead our nation's Executive Institution resolutely, and ensure that this **"Political Platform of the Royal Government"** will be successfully implemented, as this is what the Cambodian People's Party promised before the election. Additionally, I will give high attentions to the implementation of the **Six Priority Policy Programs** that will be launched immediately in 2023, which include:

(1)- Expanding healthcare services towards achieving the universal health coverage;

(2)- Providing vocational and technical trainings for youth from poor and vulnerable households across the nation;

(3)- Institutionalizing the national social assistance program for poor households, vulnerable people from poor households, and at-risk households during economic crises and emergencies;

(4)- Formulating and accelerating the implementation of the Informal Economy Development Strategy to enable them to participate in the formal economy, and to grasp the benefits from formal social protection system;

(5)- Introducing coordinating mechanism and financing program that enhance agricultural products' production, market access, and price stability at a reasonable level; and

(6)- Deploying agricultural technical officers to all communes and Sangkats that have agricultural activities across the nation and forming farmers associations in rural areas.

***Samdech, Prince, Excellencies, Ladies and Gentlemen!***

On behalf of the Royal Government, I would like to call on to the entire National Assembly, and through the National Assembly, to all compatriots, both inside and outside the country, and to the officials at all levels in the ministries and institutions of the Legislature, Executive, Judiciary, Armed Forces of all kinds, and Sub-National Institutions at all levels, as well as, all partners and development stakeholders, including bilateral and multilateral partners, the private sector, and nongovernment organizations, to fully support and actively contribute to the implementation of this **"Political Platform"**, and to make this evolve into a strong and dynamic collective movement that bring out fruitful success to our Cambodian people. In this regard, the Royal Government will launch and strive to successfully implementing the **"Pentagonal Strategy - Phase I 2023-2028"**, which is the **"Socio-Economic Policy Agenda"** of this **"Political Program"** for the Seventh Legislature of the National Assembly.

Once again, the Royal Government expresses its deepest respect and gratitude to all compatriots from everywhere, for having witnessed the actuality of our nation's

revival and progress, and for having given their unwavering faith and support to the government led by the Cambodian People's Party. With such support, the Royal Government is committed to rally all efforts to successfully carry out this historic mission of the Seventh Legislature of the National Assembly toward great success.

To the end, I would like to wish Samdech, Excellencies, President and Vice President of the National Assembly, as well as all members of the National Assembly the four gems of blessings of the Buddhist; Longevity, Nobility, Health and Strength and as well as continued success in all your endeavours to serve our nation and motherland.

***Thank you!***

*******